**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យថ្វាយព្រះសព សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យថ្វាយព្រះសពសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

១- សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត **នន្ទ ង៉ែត** ព្រះប្រធានកិត្តិយស

២- សម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អ៊ំ លឹមហេង** ព្រះអនុប្រធាន

៣- សម្តេចព្រះវនរ័តកិត្តិបណ្ឌិត **ណយ ច្រឹក** ព្រះអនុប្រធាន

៤- សម្តេចព្រះឧត្តមវង្សាកិត្តិបណ្ឌិត **ម្លូង រ៉ា** ព្រះអនុប្រធាន

៥- សម្តេចព្រះធម្មលិខិតបណ្ឌិត **សៅរ៍ ចន្ទធុល្ល** ព្រះអនុប្រធាន

៦- សម្តេចព្រះឧត្តមបញ្ញាកិត្តិបណ្ឌិត **ដួង ផង់** ព្រះអនុប្រធាន

៧- សម្តេចព្រះឧត្តមចរិយាបណ្ឌិត **ឈឹង ប៊ុនឈា** ព្រះអនុប្រធាន

៨- សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត **ឃឹម សន** ព្រះអនុប្រធាន



https://www.moj.gov.kh/kh/law-regular

| | |
|---|---|
| ៩- សម្តេចព្រះសាក្យមុនីកិត្តិបណ្ឌិត **រ័ត្ន សារឿន** | ព្រះអនុប្រធាន |
| ១០- សម្តេចព្រះព្រហ្មរតនមុនី **ពិន សែម** | ព្រះអនុប្រធាន |
| ១១- សម្តេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** | ព្រះអនុប្រធាន |
| ១២- សម្តេចព្រះមង្គលមុនីវង្ស **ហួរ ឈីវនាថ** | ព្រះអនុប្រធាន |
| ១៣- ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **វង្សី វិស្សុត** | ប្រធាន |
| ១៤- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** | អនុប្រធាន |
| ១៥- ឯកឧត្តម **ឈិន កេតនា** | អនុប្រធាន |
| ១៦- ឯកឧត្តម **ចាយ បូរិន** | អនុប្រធាន |
| ១៧- ឯកឧត្តម **នេត្រ ភក្ត្រា** | អនុប្រធាន |
| ១៨- ឯកឧត្តម **ម៉ី សំបូរ** | អនុប្រធាន |
| ១៩- អ្នកឧកញ៉ាភក្តីព្រះស្តេច **ហេង គីមគុណា** | អនុប្រធាន |
| ២០- ឯកឧត្តមនាយឧត្តមសេនីយ៍សន្តិបណ្ឌិត **ឃូ ស៊ុនឡុង** | សមាជិក |
| ២១- ឯកឧត្តម **ហ៊ុន ស៊ីថា** | សមាជិក |
| ២២- ឯកឧត្តម **សេង ទៀង** | សមាជិក |
| ២៣- ឯកឧត្តម **អេង ទូច** | សមាជិក |
| ២៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | សមាជិក |
| ២៥- ឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **ហ៊ីង ប៊ុនហៀង** | សមាជិក |
| ២៦- ឯកឧត្តមនាយឧត្តមសេនីយ៍ **ស ថេត** | សមាជិក |
| ២៧- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | សមាជិក |
| ២៨- ឯកឧត្តម **ឃួង ស្រេង** | សមាជិក |
| ២៩- ឯកឧត្តម **សេង សុមុនី** | សមាជិក |
| ៣០- ឯកឧត្តម **ឆាន់ វឌ្ឍនៈ** | សមាជិក |
| ៣១- ឯកឧត្តម **សាយ អំណាន** | សមាជិក |
| ៣២- ឯកឧត្តម **ឈួរ សុបញ្ញា** | សមាជិក |
| ៣៣- ឯកឧត្តម **ឆាត សុឆេត** | សមាជិក |
| ៣៤- ឯកឧត្តម **មៃ ស៊ីថន** | សមាជិក |
| ៣៥- ឯកឧត្តម **ឈន ថុង** | សមាជិក |
| ៣៦- ឯកឧត្តម **មាន ចាន់យ៉ាដា** | សមាជិក |
| ៣៧- ឯកឧត្តម **សុខ ពេញវុធ** | សមាជិក |
| ៣៨- ឯកឧត្តម **សេង សុភី** | សមាជិក |
| ៣៩- ឯកឧត្តម **រស់ វណ្ណី** | សមាជិក |
| ៤០- ឯកឧត្តម **អ៊ឹម រ៉ែនហាស្វាន់** | សមាជិក |
| ៤១- ឧត្តមសេនីយ៍ទោ **ប៉ែន សក្រិត្យវិទ្យា** | សមាជិក |
| ៤២- លោក **ស្នួន សុធារ៉ា** | សមាជិក |
| ៤៣- គណៈកម្មការគ្រប់គ្រងវត្តឧណ្ណាលោម | សមាជិក។ |



https://www.moj.gov.kh/kh/law-regular

**ប្រការ២ .-**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- រួមសហការជាមួយក្រសួង ស្ថាប័ននានា និងគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំពិធីបុណ្យថ្វាយព្រះសព តាមប្រពៃណីជាតិ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរបំផុត
- ពិនិត្យនិងលើកសំណើដោះស្រាយរាល់ការលំបាកនានា និងរៀបចំពិធីបុណ្យនិងពិធីតម្កល់ព្រះសព ដែលតម្កល់ក្នុងវត្តឧណ្ណាលោម
- ទទួលបន្ទុករៀបចំក្បួនដង្ហែព្រះសព តុបតែងរថយន្តបុស្បុក និងការធ្វើព្រះមេរុបូជាព្រះសព **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានស័ក្តិសមទៅនឹងព្រះកិត្តិយសរបស់ព្រះសព
- រៀបចំឱ្យមានកិច្ចការពារសន្តិសុខនិងសណ្តាប់ធ្នាប់ ក្នុងពិធីបុណ្យថ្វាយព្រះសពនិងពេលដង្ហែព្រះសព ឱ្យបានល្អប្រសើរ
- រៀបចំកម្មវិធីបុណ្យ មានជាអាទិ៍ ការអញ្ជើញថ្នាក់ដឹកនាំចូលរួមដង្ហែនិងបូជាព្រះសព ធ្វើប្លង់ដង្ហែព្រះសព
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវជាតិនិងអន្តរជាតិ ដែលអញ្ជើញចូលរួមក្នុង ពិធីបុណ្យថ្វាយព្រះសព និងគោរពព្រះវិញ្ញាណក្ខន្ធព្រះសព
- រៀបចំវេទិកាសម្រាប់ភ្ញៀវកិត្តិយស វេទិកាព្រះសង្ឃ និងពុទ្ធបរិស័ទ កៅអី តុ ទេយ្យទាន ភេសជ្ជៈ និងផ្កាខ្លឹមចន្ទន៍
- លើកគម្រោងនិងគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋនិងសប្បុរសជន ក្នុងការបម្រើឱ្យពិធីបុណ្យថ្វាយព្រះសព ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចាំបាច់សម្រាប់បម្រើឱ្យពិធីបុណ្យថ្វាយព្រះសព។

**ប្រការ៣ .-**

គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការនិងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ ដើម្បីធានាឱ្យការរៀបចំពិធីបុណ្យថ្វាយព្រះសព ប្រព្រឹត្តទៅតាមប្រពៃណីជាតិ ឱ្យស័ក្តិសមនឹងព្រះកិត្តិយសរបស់ព្រះសព។

**ប្រការ៤ .-**

គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular